**ស្ថានទូតអូស្ត្រាលី**
**ប្រចាំព្រះរាជាណាចក្រកម្ពុជា**

# <u>សេចក្តីប្រកាសព័ត៌មាន</u>

ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២៤

## ការពង្រឹងភាពជាដៃគូរបស់កម្ពុជាអូស្ត្រាលីក្នុងសកម្មភាពមីន

ឯកឧត្តម Kim Beazley នាយកសារមន្ទីរ Australian War Memorial និងជាអតីតឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការពារជាតិអូស្ត្រាលី នឹងមកទស្សនកិច្ចខេត្តសៀមរាប ពីថ្ងៃទី២៣ ដល់ថ្ងៃទី២៦ ខែវិច្ឆិកា ដើម្បីចូលរួមសន្និសីទត្រួតពិនិត្យឡើងវិញលើកទី៥ (5RC) នៃអនុសញ្ញាហាមប្រាមការប្រើប្រាស់មីនប្រឆាំងមនុស្ស (អនុសញ្ញាអូតាវ៉ា)។

ដំណើរទស្សនកិច្ចនេះ គូសបញ្ជាក់ពីការប្តេជ្ញាចិត្តយូរអង្វែងរបស់ប្រទេសអូស្ត្រាលី ដែលគាំទ្រដល់ប្រទេសកម្ពុជា ក្នុងកិច្ចខិតខំប្រឹងប្រែងបោសសម្អាតមីន ផ្តែកលើកិច្ចសហប្រតិបត្តិការជាច្រើនទសវត្សរ៍ ក្នុងគោលបំណងបង្កើតសហគមន៍ដែលមានសុវត្ថិភាព លើកកម្ពស់ការអភិវឌ្ឍ និងការសម្រេចបាននូវគោលដៅឆ្ពោះទៅរកកម្ពុជាគ្មានផលប៉ះពាល់ដោយសារមីន។

កិច្ចប្រជុំនេះប្រមូលផ្តុំថ្នាក់ដឹកនាំ អ្នកជំនាញ និងអ្នកតស៊ូមតិក្នុងការដោះមីន នៅក្នុងពិភពលោកមកជួបជុំគ្នា បង្ហាញពីភាពជាអ្នកដឹកនាំរបស់កម្ពុជាលើសកម្មភាពមីន។ កម្ពុជាបានពង្រឹងសមត្ថភាព ពីប្រទេសដែលរងផលប៉ះពាល់ខ្លាំងដោយសារគ្រាប់មីន ក្លាយជាប្រទេសតស៊ូមតិឈានមុខគេដើម្បីពិភពលោកគ្មានមីន។

តាមរយៈការប្តេជ្ញាចិត្តរបស់អាជ្ញាធរមីនកម្ពុជា និងស្ថាប័នពាក់ព័ន្ធ កម្ពុជាមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ដោយបានបោសសម្អាតផ្ទៃដីដែលមានសំណល់ជាតិផ្ទុះពីសង្គ្រាម បានជាច្រើនសន្ទឹកសន្ធាប់។ ភាពជោគជ័យនេះជាគំរូ បង្ហាញថាសកម្មភាពប្រកបដោយឆន្ទៈ ភាពជាដៃគូយុទ្ធសាស្ត្រ និងការចូលរួមរបស់សហគមន៍ អាចឈានទៅរកលទ្ធផលជាក់ស្តែងប្រាកដមែន។

ដំណើររបស់កម្ពុជាឆ្ពោះទៅរកការក្លាយជាប្រទេសគ្មានផលប៉ះពាល់ដោយសារមីនជាឧទាហរណ៍ដ៏គួរអោយស្ញប់ស្ញែង។ អូស្ត្រាលីមានមោទនភាព ដែលបានចូលរួមគាំទ្រកិច្ចខិតខំប្រឹងប្រែងទាំងនេះ។ យើងទាំងអស់គ្នាកំពុងធ្វើការឆ្ពោះទៅរកចក្ខុវិស័យរួមគ្នាដើម្បីសុវត្ថិភាព វិបុលភាព និងសេចក្តីថ្លៃថ្នូរ សម្រាប់យើងទាំងអស់គ្នា។

កិច្ចប្រឹងប្រែងបោសសម្អាតមីនរបស់អូស្ត្រាលីស្របតាមការប្តេជ្ញាចិត្តយ៉ាងទូលំទូលាយរបស់ខ្លួនចំពោះសន្តិភាព និងសន្តិសុខក្នុងតំបន់។ អស់រយៈពេលជាង ៣០ ឆ្នាំមកនេះ ប្រទេសអូស្ត្រាលីបានផ្ត

ល់ថវិកាប្រមាណ ១០០ លានដុល្លាអូស្ត្រាលី ដើម្បីគាំទ្រសកម្មភាពមីននៅកម្ពុជា ការផ្គត់ផ្គង់ឧបករណ៍ទំនើប ការបណ្តុះបណ្តាលអ្នកដោះមីនក្នុងប្រទេស និងការផ្តល់មូលនិធិដល់កម្មវិធីដែលផ្តល់អាទិភាពដល់ការស្តារ និងសមាហរណកម្មជនរងគ្រោះដោយសារមីន។ ជំនួយរបស់អូស្ត្រាលីបានជួយកម្ពុជា បោះជំហានជាខ្លាំងទៅរកការកាត់បន្ថយតំបន់ដែលរងផលប៉ះពាល់ដោយសារមីន លើកកម្ពស់ការអភិវឌ្ឍជនបទនិងកំណើនសេដ្ឋកិច្ច និងប្រែក្លាយអតីតសមរភូមិឱ្យទៅជាដីដាំដុះដំណាំកសិកម្ម និងអភិវឌ្ឍន៍សហគមន៍។

កម្ពុជា និងអូស្ត្រាលីរួមគ្នាធ្វើការឆ្ពោះទៅរកអនាគតដែលគ្មានផលប៉ះពាល់ដោយសារមីន ដែលសហគមន៍អាចរីកចម្រើន និងអភិវឌ្ឍបាន។

**ទំនាក់ទំនងព័ត៌មាន៖** Media.Cambodia@dfat.gov.au